ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

បណ្ណបច្ចេកទេស ២០១៤/០៣

# ជំងឺជ្រុះស្លឹកករីណេស្ប៉រ៉ា
## Corynespora Leaf fall disease



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងការពារ

## ១. លក្ខណៈទូទៅ

ក្នុងពេលបច្ចុប្បន្ន ជំងឺជ្រុះស្លឹកករីណេស្ប៉រ៉ា (*Corynespora* leaf fall) ត្រូវបានចាត់ទុកជាជំងឺបំផ្លាញដ៏ធំធេងមកលើដំណាំកៅស៊ូ។ ជំងឺនេះបានកើតឡើងនៅប្រទេស ឥណ្ឌា ម៉ាឡេស៊ី ថៃ ស្រីលង្កា ឥណ្ឌូនេស៊ី បង់ក្លាដេស វៀតណាម កាម៉ារូន នីហ្សេរីយ៉ានិងកូដឌីវ័រ ហើយថ្មីៗនេះក៏មានវត្តមាននៅកម្ពុជាផងដែរ។ នៅប្រទេសដាំកៅស៊ូជាច្រើន ជំងឺនេះបង្កមហន្តរាយខ្លាំងតែក្លូនមួយចំនួនប៉ុណ្ណោះ។ នៅស្រីលង្កាជំងឺនេះបានបង្កមហន្តរាយជាង៣០០០ហិកតានៃក្លូនដែលងាយទទួលជំងឺ ជាពិសេសក្លូន RRIC103 ទាំងនៅក្នុងចម្ការកៅស៊ូថ្មីក៏ដូចក្នុងចម្ការកៅស៊ូចាស់។ រីឯនៅវៀតណាមជំងឺនេះវាយប្រហារធ្ងន់ធ្ងរលើក្លូន RRIV4 ។ ជំងឺនេះរាតត្បាតលើស្លឹកកៅស៊ូគ្រប់វ័យពេញមួយឆ្នាំៗ។

## ២. រោគសញ្ញាជំងឺ

ជំងឺជ្រុះស្លឹកករីណេស្ប៉រ៉ា បង្កឡើងដោយផ្សិត *Corynespora cassiicola* ។ ផ្សិតនេះមានឥទ្ធិពលទាំងនៅលើស្លឹកខ្ចីនិងស្លឹកចាស់។ នៅក្រោមលក្ខខណ្ឌអាកាសធាតុអំណោយផល ជំងឺនឹងរីករាលដាលបណ្តាលឲ្យជ្រុះស្លឹក។

រោគសញ្ញាដំបូងនៅលើស្លឹកលេចឡើងនូវស្នាមពណ៌ត្នោតប្រផេះនិងមានស្នាមអុជច្រើនភ្ជាប់គ្នាជាផ្ទាំងដែលប្រមូលផ្តុំផ្សិតរីកធំឡើងបង្ករជាដំបៅ (lesions) ខ្មៅចង្រ្កួញនិងមានទ្រង់ទ្រាយមិនដូចគ្នា។

## ៣. លក្ខខណ្ឌកើតជំងឺ

ជំងឺរីករាលដាលដោយសារស្ព័រហើយតាមខ្យល់។ ក្នុង១សង់ទីម៉ែត្រការ៉េនៃស្លឹកកើតជំងឺមានស្ព័រប្រហែល១២០០ហើយស្ព័រទាំងនេះអាចមានជីវិតរស់នៅបានរយៈពេល១ខែទោះបីស្លឹកជ្រុះក៏ដោយ ដែលបង្ហាញថាផ្សិតអាចធន់នឹងលក្ខខណ្ឌមិនល្អ។ សីតុណ្ហភាពល្អបំផុតសម្រាប់ស្ព័រលូតលាស់គឺ៣០°C ប៉ុន្តែ ផ្សិតអាចកើតមាននៅសីតុណ្ហភាព១៥°C -៤០°C ផងដែរ។ ក្នុងករណីសំណើមខ្ពស់មានអំណោយផលដល់ការរីករាលដាលនៃជំងឺ ប៉ុន្តែបើសំណើមទាបជំងឺមិនរីករាលដាលខ្លាំងនោះទេ។



នៅលើស្លឹកចាស់លក្ខណៈពិសេសនៃជំងឺមានស្នាមពណ៌ត្នោត ឬក្រមៅលើទ្រនុងស្លឹកដែលមានសណ្ឋានដូច "ឆ្អឹងត្រី" (fishbone)។ ជាទូទៅស្លឹកកើតជំងឺបានប្តូរពណ៌ពីបៃតងទៅជាលឿងដោយសារក្លរ៉ូហ្វីលត្រូវបានបំផ្លាញ ហើយចុងក្រោយស្លឹកប្រែពណ៌ក្រហមនិងជ្រុះ។ ការជ្រុះស្លឹកច្រើនដងអាចបណ្តាលឲ្យកើតជំងឺ dieback នៅលើត្រួយនិងមែក ករណីធ្ងន់ធ្ងរធ្វើឲ្យងាប់ដើមទាំងស្រុង។



## ៤. ការរាលដាលជំងឺ

នៅថ្នាលបណ្តុះកូន (Nursery) កូនកៅស៊ូមិនទាន់បំបៅផាយរង់នូវជំងឺ។ ចំណែកនៅច្បារពូជនិងចម្ការកៅស៊ូ ជំងឺពតត្បាតភាគច្រើនលើក្លូន៖ RRIC52, RRIC103, RRIC104, RRIC110, RRIM725, RRIC106, PR107, PR255, PB235, PB260, PB311, PB86, PB255, RRII300, RRII305,...

ចំពោះក្លូនដែលធន់នឹងជំងឺមាន៖ RRIC100, RRIC102, RRIM600, PB217,...

## ៥. ការការពារនិងព្យាបាល ថ្នាលបណ្តុះកូន

ដើម្បីទប់ស្កាត់ជំងឺនេះ នៅថ្នាលបណ្តុះកូន (Nursery) គេមិនគួរប្រើដើងទម្រចេញពីគ្រាប់កៅស៊ូនៃបណ្តាក្លូនផាយរង់នូវជំងឺមានដូចជា៖ PR107, PR255, PB235, PB260, PB311, PB86,...



ការពារការកកើតជំងឺនៅថ្នាលបណ្តុះកូនដោយការបាញ់ថ្នាំក្នុងរយៈពេល៥ថ្ងៃម្តងនូវប្រភេទថ្នាំ៖

- ឌីតានអឹម៤៥ (Dithane M45) កម្រិត 0.3% (3g/1l ទឹក)
- កាប់តាន (Captan)កម្រិត 0.4% (4g/1l ទឹក)
- អង់ត្រាក់កុល (Antracol) កម្រិត 0.4% (4g/1l ទឹក)

## ច្បារពូជនិងចម្ការកៅស៊ូ

នៅច្បារពូជនិងចម្ការកៅស៊ូគេបាញ់ថ្នាំ ១សប្តាហ៍ម្តងនូវប្រភេទថ្នាំ៖

- ឌីតានអឹម៤៥ (Dithane M45) កម្រិត 0.3% (3g/1l ទឹក)
- ម៉ង់កូសែប (Mancozeb) កម្រិត 0.3% (3g/1l ទឹក)
- កាប់តាន (Captan) កម្រិត 0.4% (4g/1l ទឹក)
- អង់ត្រាក់កុល (Antracol) កម្រិត 0.4% (4g/1l ទឹក)
- ហ្ស៊ីនែប (Zineb) កម្រិត 0.2-0.75%
- ប្រូពីនែប (Propineb) កម្រិត 0.5% ។


**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋាន: អគារលេខ ៩ មហាវិថី ប៉ែននុត (២៨៩) សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ ១៣៣៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៨៨២ ៨៣១

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh